# មេរៀនទី ១២១: ព្រះយេស៊ូវមានបន្ទូលទៅកាន់ស្ត្រីសាសន៍សាម៉ារី

## យ៉ូហាន ៤:៥-៤២

**គោលបំណង៖** ព្រះយេស៊ូវជាទឹករស់បំពេញដល់ជីវិតយើង។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៤:១៤ក** *"តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ទឹករស់របស់អ្នក គឺជាការដែលអ្នកមានទំនាក់ទំនងជាមួយព្រះយេស៊ូវ។ ពេលអ្នករីកចម្រើនក្នុងចំណងមិត្តភាពរបស់អ្នកជាមួយព្រះយេស៊ូវតាមរយៈការអធិស្ឋាន និងពេលវេលានៅក្នុងព្រះគម្ពីរអ្នកនឹងរកឃើញភាពស្រស់ស្រាយ សូម្បីតែក្នុងគ្រាលំបាកក៏ដោយ។ ស្ត្រីសាសន៍សាម៉ារីគឺជាចំនុចមួយដើម្បីប្រាប់អ្នករាល់គ្នាថានាងស្គាល់អំពីព្រះយេស៊ូវ។ នាងបានរកឃើញ«ទឹករស់»ហើយនាងចង់ឲ្យមនុស្សជាទីស្រឡាញ់ទាំងអស់«ភ្លក់»នូវអ្វីដែលជាចំណងមិត្តភាពជាមួយនឹងព្រះយេស៊ូវមានលក្ខណៈបែបណា។ តើអ្នកកំពុងចែករំលែកទឹករស់ជាមួយអ្នកណា? សូមព្រះប្រទានឲ្យអ្នកនូវឈ្មោះមនុស្សពីរនាក់ ដែលអ្នកអាចចែករំលែកពីព្រះយេស៊ូវទៅកាន់ពួកគេបាន។

**ចំរៀង៖** ១. នៅរស់ ២.មានទន្លេជីវិត ៣. ខ្ញុំដឹងថា

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «បំពេញកែវ»**

**សម្ភារៈដែលត្រូវការ៖** កែវ៤ ទុយោ២ និងតុ




១. ចែកកុមារជា២ក្រុម ហើយឲ្យពួកគេឈរជាជួរ។

២. ចាក់ទឹកក្នុងកែវ ២ ហើយកែវ២ទៀតទុកឲ្យនៅទទេ ហើយដាក់ក្បែរគ្នានោះ និងទុយោ២ផងដែរ។ ឲ្យកុមារឈរចម្ងាយ ៣ម៉ែត្រពីតុ។

៣. នៅពេលដែលគ្រូនិយាយថា ១ ២ ៣ កុមារទីមួយនៃក្រុមទាំងពីរត្រូវរត់ទៅកាន់តុ ហើយប្រើទុយោដើម្បីបញ្ជូនទឹកទៅដាក់ក្នុងកែវទទេ។ ពួកគេគឺអាចប្រើបានតែដៃម្ខាងប៉ុណ្ណោះ។ ពួកគេអាចប្រើទុយោដាក់ចូលទៅក្នុងកែវដែលមានទឹក ហើយប្រើចង្អុលដៃរបស់ពួកគេបិតទុយោផ្នែកខាងលើ ហើយបន្ទាប់មកយកទឹកនោះទៅដាក់ក្នុងកែវទទេ។

៤. កុមារម្នាក់អាចប្រើពេល ៣០វិនាទី ក្នុងការជញ្ជូនទឹកដាក់បំពេញកែវ។

៥. សូមលេងល្បែងនេះរហូតដល់កុមារបានលេងគ្រប់ៗគ្នា។

៦. ក្រុមណាដែលអាចជញ្ជូនទឹកដាក់ចូលទៅក្នុងកែវបានច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវគឺជាទឹករស់ ដែលតែងតែបំពេញនូវសេចក្ដីត្រូវការរបស់យើង។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងទៅជាយ៉ាងណាប្រសិនបើអ្នកចង់ញ៉ាំតែម្ហូបហើយអត់ចង់ញ៉ាំទឹក? តើអ្នកដឹងទេថាមនុស្សនឹងស្លាប់ប្រសិនបើពួកគេមិនញ៉ាំទឹក? ទឹកបំពេញចិត្តយើងពេលយើងស្រេកទឹក។ គ្រប់ភាវៈមានជីវិតទាំងអស់ត្រូវការទឹកដើម្បីរស់។ ថ្ងៃនេះយើងនឹងរៀនថា ព្រះយេស៊ូវជាទឹករស់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះ គឺនិយាយអំពីស្ត្រីសាសន៍សាម៉ារីម្នាក់ដែលជឿលើព្រះ ប៉ុន្តែនាងមិនស្គាល់ព្រះយេស៊ូវទេ។ ថ្ងៃមួយព្រះយេស៊ូវមានការហត់នឿយ និងស្រេកទឹក ពេលទ្រង់កំពុងធ្វើដំណើរឆ្លងកាត់ស្រុកសាម៉ារី។ ព្រះអង្គអង្គុយនៅមាត់អណ្ដូងខណៈពួកសិស្សទៅរកអាហារ។ ពេលនោះមានស្ត្រីម្នាក់មកដងទឹកពីអណ្ដូងហើយព្រះយេស៊ូវបានសុំទឹកនាងសោយ។ ដូច្នេះនាងក៏បានថ្វាយទឹកខ្លះដល់ទ្រង់។

បន្ទាប់មក ព្រះយេស៊ូវប្រាប់នាងថា ទ្រង់ចង់ប្រទានទឹករស់ដល់នាង។ ព្រះអង្គកំពុងមានបន្ទូលអំពីខ្លួនទ្រង់។ ទ្រង់មានន័យថា ទ្រង់ចង់បំពេញអ្វីដែលល្អដល់នាង ដូចជាសេចក្ដីស្រឡាញ់ សន្តិភាព និងការអត់ទោសរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវបានដឹងថាមានតែព្រះអង្គប៉ុណ្ណោះ ដែលអាចបំពេញចិត្តនាងបាន។ ទ្រង់ចង់ផ្ដល់ឱ្យនាងនូវជីវិតដ៏អស់កល្បជានិច្ច និងសុភមង្គលពិតប្រាកដ ដែលអាចរកបានដោយការជឿលើព្រះយេស៊ូវប៉ុណ្ណោះ។

**យ៉ូហាន ១៤:១៣-១៤** “ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា អស់អ្នកណាដែលផឹកទឹកនេះនឹងត្រូវស្រេកទៀត តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យនោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឲ្យនឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច។”

ព្រះយេស៊ូវបានប្រាប់ស្ត្រីសាសន៍សាម៉ារីអំពីរឿងផ្ទាល់ខ្លួនរបស់នាង ជារឿងដែលទ្រង់មិនអាចដឹងបាន លុះត្រាតែទ្រង់ជាព្រះ។ ព្រះអង្គដឹងថានាងឯកោ ហើយស្វែងរកស្នេហាមិនបានសមដូចបំណង។ ព្រះយេស៊ូវចង់ប្រទានពរឲ្យនាងនូវអ្វីដែលនាងមិនអាចទទួលបានសម្រាប់ខ្លួននាង។

ព្រះយេស៊ូវចង់បំពេញចិត្តយើង។ តើអ្នកត្រូវការអ្វីនៅថ្ងៃនេះ? តើអ្នកឯកាមែនទេ? ខឹងនឹងនរណាម្នាក់មែនទេ? តើអ្នកត្រូវការជំនួយក្នុងការអភ័យទោសដល់នរណាម្នាក់ទេ? ប្រហែលជាអ្នកត្រូវអត់ទោសឱ្យខ្លួនឯង។ តើអ្នកត្រូវការជំនួយក្នុងការស្ដាប់បង្គាប់ឪពុកម្ដាយ ឬមានចិត្តសប្បុរស ឬអត់ធ្មត់? តើថ្ងៃនេះអ្នកខ្វះអ្វីខ្លះ? ព្រះយេស៊ូវប្រទានរបស់ល្អដល់យើង។ ព្រះយេស៊ូវបំពេញចិត្តយើងដោយសេចក្ដីស្រឡាញ់របស់ទ្រង់ និងជីវិតដែលទ្រង់ប្រទានឲ្យយើង។ ព្រះយេស៊ូវជាទឹករស់ ហើយទ្រង់បំពេញចិត្តយើង។

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវនៅឯណានៅក្នុងរឿងនេះ? *សាម៉ារី*

២. តើទ្រង់កំពុងមានបន្ទូលជាមួយអ្នកណា? *ស្ត្រីសាសន៍សាម៉ារីម្នាក់*
៣. តើព្រះអង្គសុំនាងឲ្យអ្វីទៅព្រះអង្គ? *ទឹកខ្លះ*
៤. តើព្រះអង្គមានបន្ទូលថាទ្រង់អាចផ្ដល់ឱ្យនាងអ្វីខ្លះ? *ទឹករស់*
៥. តើទឹករស់ជាអ្វី? *ព្រះយេស៊ូវគឺជាអ្នកដែលអាចបំពេញតម្រូវការទាំងអស់របស់យើង*

## ៧. ល្បែងកំសាន្ត «ប្រៃ ឬផ្អែម»

**សម្ភារៈដែលត្រូវការ៖** កែវ២ ទឹក អំបិល និងស្ករ




១. ចែកកុមារជាពីរក្រុម ។
២. ចាក់ទឹកចូលក្នុងកែវពីរ ដោយកែវមួយដាក់អំបិល ហើយកែវមួយទៀតដាក់ស្ករ។
៣. ឲ្យកុមារម្នាក់មកពីក្រុមនីមួយៗ រួចគ្រូសួរកុមារឲ្យជ្រើសរើសកែវណាមួយ បើគ្រូឲ្យរើសយកទឹកស្ករសិស្សត្រូវចង្អុលកែវដែលមានទឹកស្ករ បើគ្រូឲ្យរើសទឹកអំបិលសិស្សត្រូវចង្អុលកែវទឹកអំបិល ។ បើសិនជាកុមារជ្រើសរើសត្រូវតាមអ្វីដែលគ្រូប្រាប់ឲ្យរើសក្រុមពួកគេនឹងទទួលបាន ១ ពិន្ទុ។




៤. គ្រូត្រូវប្ដូរទីតាំងរបស់កែវទាំងពីរសម្រាប់អ្នកលេងបន្ទាប់។
៥. បន្តលេងល្បែងនេះរហូតដល់កុមារបានលេងល្បែងនេះគ្រប់ៗគ្នា។
៦ សូមពន្យល់កុមារថា ព្រះយេស៊ូវគឺជាទឹករស់ ហើយទ្រង់គឺតែងតែផ្ដល់របស់ល្អឲ្យយើង ដើម្បីបំពេញនូវសេចក្ដីត្រូវការរបស់យើង។

## ៨. ខគម្ពីរចងចាំ យ៉ូហាន ៤:១៤ក

## ៩. ហត្ថកម្ម «ទឹករស់»

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម កន្ត្រៃ កាវ កូលរ័ផាត់ពណ៌



១. ផាត់ពណ៌អណ្ដូងដែលនៅលើក្រដាសហត្ថកម្ម។
២. កាត់រូបអណ្ដូងនិងដំបូលដែលមានខគម្ពីរចងចាំ។
៣. បត់អណ្ដូងហើយបិតកាវ ដូច្នេះរូបអាចឈរដោយខ្លួនឯងបាន។
៤. បិតកាវដំបូលនៅលើគេ។
៥. នៅពេលពួកគេអានខគម្ពីរនៃការចងចាំជាមួយគ្នា សូមរំឭកកុមារថា ព្រះយេស៊ូវជាទឹករស់។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*





**យ៉ូហាន ៤៖១៤**

*“តែអ្នកណាដែលផឹកទឹកខ្ញុំ
ឲ្យនោះនឹងមិនស្រេកទៀត
ឡើយ។”*